# សំបុត្រពីអ្នកនិពន្ធ

## ការបង្កើនគុណភាពជីវិតរបស់កសិករអ្នកធ្វើស្រែតាមទ្រឹស្តី សមពល

ដូចបានរៀបរាប់ ពីលេខមុនរួចមកហើយការកសាងគុណ-ភាពជីវិតរបស់កសិករគឺអាស្រ័យលើការកសាង ឬការសន្សំ នូវសមពល (ស: សុខភាព, ម: មមោក, ព: ពូជស្រូវ, ល: លុយ)។ មានន័យថា នៅពេល <u>សមពល</u> កាន់តែប្រសើរ នាំឲ្យគុណភាពជីវិតកាន់តែប្រសើរ ឬកសិករកាន់តែចាស់ ជីវិតកាន់តែស្រួល។ កន្លងមក ខ្ញុំបានធ្វើការពន្យល់បកស្រាយពីគំនិតមួយចំនួនទាក់ទង ទៅនឹងការកសាងសុខភាព និងការសាងសារធាតុមមោក នៅដីស្រែទាប់លើ ។ នៅពេលនេះ ខ្ញុំសូម លើកយកប្រធានបទ **ពូជ** មកបង្ហាញដោយសង្ខេបដូចខាងក្រោមនេះ។




ដើម្បីឲ្យពី ១ឆ្នាំ ទៅ ១ឆ្នាំ កសិករអាចទទួលផលស្រូវបានច្រើន ហើយមិនមានភាពអាស្រ័យលើការទិញពូជនាំចូលពីខាងក្រៅ ឬដើម្បីឲ្យកសិករមានភាពជាម្ចាស់លើពូជស្រូវ ដែលជាអាយុជីវិតរបស់កសិករ ការជ្រើសរើស និងទុកពូជជារឿងសំខាន់បំផុត។ ដើម្បីឲ្យកសិករយើងបានពូជកាន់តែសុទ្ធល្អពី ១ឆ្នាំ ទៅ ១ឆ្នាំ ខ្ញុំសូមណែនាំនូវគំនិតសាមញ្ញ។ មួយចំនួនដូចខាងក្រោមនេះ (សូមមើលរូបភាពបន្ថែម):

- ជ្រើសរើសកួរស្រូវណា ដែលល្អៗដូចគ្នាទុកធ្វើពូជជាពិសេស កួរវែងមានស្មែងច្រើន និងគ្រាប់ពេញច្រើន

- ដាច់ខាតកុំបោកបែនស្រូវ ដោយប្រើកម្លាំងខ្លាំង ពីព្រោះវាធ្វើឲ្យប្រួសដល់មេក្រាអង្គុរ នៅក្នុងគ្រាប់ និងពន្លកស្រូវ ដែលនាំឲ្យស្រូវដុះលូតលាស់មិនបានល្អពេញលក្ខណៈ (យើងអាចប្រៀបធៀបគ្រាប់ស្រូវដូចជា ស្ត្រីមានផ្ទៃពោះ ដែលពន្លកប្រៀបដូចកូនដែលក្នុងពោះ ហើយមេក្រាអង្គុរប្រៀបដូចជា ចំណី ឬទឹកដោះសំរាប់ចិញ្ចឹមកូនង៉ែត ពេលស្រូវចាប់ដុះពន្លក)។
- យកល្អចងព្យួរក្នួរស្រូវ ឬប្រឡះវាថ្នមៗ ហើយដាក់ក្នុងស្បូក ឬកូនបាវក្រណាត់ដែលមានខ្យល់ចេញចូលល្អ។
- ធ្វើការបេះស្មែងខាងលើ និងស្មែងខាងចុងចំនួន ២-៣ ស្មែងចេញ ដោយទុកតែគ្រាប់នៅស្មែងកណ្តាលសំរាប់យកទៅធ្វើពូជបន្ត។ បើកាន់តែឲ្យល្អបន្ថែមទៀតគឺ យកតែគ្រាប់ពេញៗរបស់ស្មែងកណ្តាលក្នួរសំរាប់ទុកធ្វើពូជបន្ត។

ការរើសពូជមួយក្នួរៗ មួយស្មែងៗ និងមួយគ្រាប់ៗ ត្រូវការឧស្សាហ៍ព្យាយាម យកចិត្តទុកដាក់បន្តិច តែបើយើងបានគ្រាប់ល្អមួយគ្រាប់ៗវានាំឲ្យយើងបានស្រូវដែលមួយគុម្ពមានផលរាប់ពាន់ ឬអាចឈានដល់រាប់ម៉ឺនគ្រាប់ (ឧទាហរណ៍ ស្រូវល្អមួយគ្រាប់អាចដុះបែកខ្នែងបាន ២០-៤០ ក្នួរ ហើយមួយក្នួរមានគ្រាប់ពី ២៥០-៣៥០ គ្រាប់ ឬស្រូវមួយគុម្ពដែលចេញពីមួយគ្រាប់អាច នាំមកនូវ ៥,០០០ ទៅ ១៤,០០០ គ្រាប់ ឬលើសនេះថែមទៀត) ។

សរុបមកដើម្បីអាចបានពូជស្រូវកាន់តែល្អ គឺកសិករត្រូវការរើសតែក្នួរដែលល្អ យកតែស្មែងល្អៗ (ស្មែងកណ្តាល) និងគ្រាប់ដែលពេញល្អដូចគ្នា សំរាប់ទុកប្រើជាពូជ។ ប្រសិនបើកសិករធ្វើរបៀបនេះរាល់ឆ្នាំពូជស្រូវកាន់តែល្អទៅៗ ហើយផលស្រូវនឹងកើនជាប់ជានិច្ច។

ការមានពូជកាន់តែល្អ ផ្សាភ្ជាប់ជាមួយការកសាងនូវមមោកនៅដីស្រទាប់លើ ឲ្យបានកាន់តែប្រសើរ ពី១ឆ្នាំ ទៅ ១ឆ្នាំ (ដូចបានរៀបរាប់កាលពីលេខមុន) នាំឲ្យយើងបានផលស្រូវកាន់តែច្រើន និងចំណាយកាន់តែតិច។ នៅទស្សនាវដ្តីលេខក្រោយ ខ្ញុំនឹងធ្វើការរៀបរាប់បន្ថែមលើ ផ្នែកទី ៤ របស់សមពល គឺ **ល** (លុយ) ។

" ពូជស្រូវកាន់តែសុទ្ធល្អ បង្កឱ្យផលកាន់តែខ្ពស់ "

**បណ្ឌិត យ៉ង សាំងកុមារ**